ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ.....៣៦៨.៣.....ប៩..ស្រក.............

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង-ស្ថាប័ន សម្រាប់គ្រប់គ្រងការរៀបចំបណ្តាញខ្សែកាប្លិ៍-ខ្សែកាប្លិ៍អុបទិកទូរគមនាគមន៍ នៅទីប្រជុំជន ទីក្រុង រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងលិខិតលេខលេខ ២០៦/១៨ ធត.រ.ក្រ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលារាជធានីភ្នំពេញ
- យោងលិខិតលេខ ៦៥៨ សក.អហេ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- យោងលិខិតលេខ ១៧៣០ សជណ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ២៣៧៤ ដនស/អរប/ពុ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងលិខិតលេខ ១៣១០ ព.ម ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងព័ត៌មាន
- យោងលិខិតលេខ ០៨៩ ធ.ត ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- យោងលិខិតលេខ ៥៩៣៤ អក.អច ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ របស់អគ្គិសនីកម្ពុជា
- យោងតាមការងារចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**ប្រការ ១.**_

បង្កើតគណៈកម្មការអន្តរក្រសួង-ស្ថាប័នសម្រាប់គ្រប់គ្រងការអូសរាយបណ្តាញខ្សែកាប្លិ៍-ខ្សែកាប្លិ៍អុបទិកទូរគមនាគមន៍ នៅទីប្រជុំជន ទីក្រុង រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **សុខ ពុទ្ធិវុធ** | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម **ស៊ុយ សេរីវុទ្ធ** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣. ឯកឧត្តម **ជា មាលិត** | អនុរដ្ឋលេខាធិការ ក្រសួង ប.ទ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ៤. ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥. ឯកឧត្តម **អ៊ឹម បូរី** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៦. ឯកឧត្តម **លី វណ្ណាសុទ្រា** | អនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧. ឯកឧត្តម **ម៉ុង ចរិយា** | ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៨. ឯកឧត្តម **សន វី** | អគ្គនាយកទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៩. ឯកឧត្តម **ឈាន លាង** | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១០. លោក **សំរិទ្ធ សុវិចិត្រា** | អគ្គនាយករង នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |
| ១១. លោក **ហង់ ទូច** | នាយករង នៃនាយកដ្ឋានអាជីវកម្មចែកចាយនៃអគ្គិសនីកម្ពុជា | សមាជិក |
| ១២. ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍រាជធានី ខេត្ត | | សមាជិក |
| ១៣. លោក **ហេង សុគន្ធ** | អនុប្រធាននាយកដ្ឋាន | លេខាធិការ |

**ប្រការ ២.**_

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- រៀបចំផែនការមេ និងស្តង់ដារបច្ចេកទេសពាក់ព័ន្ធនឹងការអូសរាយបណ្តាញខ្សែកាប្លិ៍-ខ្សែកាប្លិ៍អុបទិកទូរគមនាគមន៍
- ត្រួតពិនិត្យបទដ្ឋាន ស្តង់ដារបច្ចេកទេសនៃការអូសរាយបណ្តាញខ្សែកាប្លិ៍-ខ្សែកាប្លិ៍អុបទិកទូរគមនាគមន៍គ្រប់ប្រភេទ
- ចេញកាលវិភាគដើម្បីរៀបចំ និងអនុវត្តផែនការមេ ជូនបណ្តាប្រតិបត្តិករទូរគមនាគមន៍
- ត្រួតពិនិត្យការងារខ្សែកាប្លិ៍ និងខ្សែកាប្លិ៍អុបទិកជាក់ស្តែងនៅតាមបណ្តារាជធានី ខេត្ត
- ត្រួតពិនិត្យគុណភាពប្រព័ន្ធបែងចែកសេវាអ៊ីនធឺណិត បណ្តាញខ្សែកាប្លិ៍ និងខ្សែកាប្លិ៍អុបទិកដែលកំពុងប្រតិបត្តិការ និងប្រើប្រាស់នៅគ្រប់រាជធានី ខេត្ត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អនុវត្តការងារផ្សេងទៀតដែល ឯកឧត្តមរដ្ឋមន្ត្រី ប្រគល់ឲ្យ ។

**ប្រការ ៣.**_

គណៈកម្មការនេះ អាចបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីជាជំនួយក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ២ ខាងលើ ។

**ប្រការ ៤.**_

គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៥.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.**_

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គាធិការ ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា អគ្គនាយកទូរគមនាគមន៍កម្ពុជា គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ០១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ [illegible] ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

<u>ចម្លងជូន</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៦

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ